**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៩៤ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

## សម្រេច

**មាត្រា១៖**

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំណាមលៀរ លើផ្ទៃដីសរុបចំនួន ៥០០ហិកតា (ប្រាំរយហិកតា) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តមណ្ឌលគិរី សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ខេ ភីស អ៊ិនវេសមេន (ខេមបូឌា)** (K PEACE Investment (Cambodia) Co., Ltd) ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម និងដាំដំណាំកៅស៊ូ រយៈពេល៨០ឆ្នាំ ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ៩៩៤សជណ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០១១ ជាឧបសម្ព័ន្ធ។

www.pheakdeylaw.com

**មាត្រា២៖**

ត្រូវបាននិរាករណ៍លិខិតលេខ ៩៣ សជណ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១១ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី និងលិខិត បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ។

ត្រូវបាននិរាករណ៍អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព របស់ក្រុមហ៊ុន**សិទ្ធី អេគ្រីខលឈើរ ផ្លេនថេសិន**។

**មាត្រា៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

www.pheakdeylaw.com